# វិធីសាស្ត្រស្រាវជ្រាវ

# Research Methods



# មាតិកា

I. គោលបំណង

II. តើការស្រាវជ្រាវមានន័យដូចម្តេច?

III. ហេតុអ្វីត្រូវចាំបាច់ស្រាវជ្រាវ?

IV. ការជ្រើសរើសវិធីសាស្ត្រស្រាវជ្រាវ

V. ទម្រង់សំណើរស្រាវជ្រាវ

VI. ឯកសារពិគ្រោះ

# I. គោលបំណង

- គោលបំណងសំខាន់របស់មេរៀននេះគឺ ការយល់ដឹងអំពីវិធីស្រាវជ្រាវបែបវិទ្យាសាស្ត្រ។
- រៀបចំសំណើរស្រាវជ្រាវ (Research proposal)
- ផ្តល់គំនិតថ្មីក្នុងការរៀបចំគំនិតស្រាវជ្រាវ
- យល់ដឹងអំពីជំហានអនុវត្តនិងដំណើរការនៃការស្រាវជ្រាវ
- យល់ដឹងអំពីជំហានពិសោធន៍បែបវិទ្យាសាស្ត្រ



# II. តើស្រាវជ្រាវមានន័យដូចម្តេច?



- ជាការរុករកដែលមានលក្ខណៈជាប្រព័ន្ធ ឬជាការសិក្សាលើសម្ភារៈ និងធនធានឬជាការបង្កើតព្រឹត្តការណ៍ ដើម្បីឈានដល់ការសន្និដ្ឋានថ្មី។
- ការស្រាវជ្រាវជាការសិក្សាយ៉ាងប្រុងប្រយ័ត្ន និងលម្អិតទៅលើបញ្ហាជាក់លាក់ណាមួយដោយប្រើវិធីវិទ្យាសាស្ត្រ។
- ហេតុនេះហើយដើម្បីចាប់ផ្តើមស្រាវជ្រាវ អ្នកត្រូវមាន ឬឃើញបញ្ហាដែលត្រូវងាកមកគិតសំណួរ។

# III. ហេតុអ្វីយើងចាំបាច់ត្រូវតែស្រាវជ្រាវ ?

- ដើម្បីប្រសិទ្ធភាពនៃការអនុវត្តការងាររបស់អ្នក (Action Research)
- ដើម្បីបង្កើតប្រាក់ចំណូលនៃការងារប្រកបអាជីវកម្ម (Business Research)
- ដើម្បីរុករកអ្វីមួយថ្មី
- ដើម្បីបង្ហាញអ្វីមួយ
- ដើម្បីបំពេញការចេះដឹង
- ដើម្បីដោះស្រាយបញ្ហា
- ដើម្បីកសាងចំណេះដឹង



# IV. ការជ្រើសរើសវិធីសាស្ត្រស្រាវជ្រាវ

A. វិធីសាស្ត្រស្រាវជ្រាវបែបគុណវិស័យ (Qualitative Research) ដើម្បីរុករកអាកប្បកិរិយា ឥរិយាបទ និងបទពិសោធន៍តាមរយៈសម្ភាសន៍ ឬពិភាក្សាក្រុម (FDG)។ វិធីសាស្ត្រស្រាវជ្រាវបែបគុណវិស័យបង្ហាញឲ្យឃើញក្នុង៖

- ស្រាវជ្រាវសកម្ម (Action research): អ្នកស្រាវជ្រាវ១ក្រុមធ្វើការស្រាវជ្រាវជាមួយគ្នាសហការគ្នាយ៉ាងជិតស្និតដើម្បីអភិវឌ្ឍគំនិត។
- ការស្រាវជ្រាវបែបនវិទ្យា (Ethnography research): ពិពណ៌នា និងបកស្រាយអាកប្បកិរិយា។

# IV. ការជ្រើសរើសវិធីសាស្ត្រស្រាវជ្រាវ

B. វិធីសាស្ត្រស្រាវជ្រាវបែបបរិមាណវិស័យ (Quantitative Research): ការស្រាវជ្រាវទ្រឹស្តីមូលដ្ឋាន។ អភិវឌ្ឍទ្រឹស្តីនិងរំលឹកទ្រឹស្តីសម្រាប់ប្រមូលទិន្នន័យ។

❖ វិធីស្រាវជ្រាវបែបគុណវិស័យ ប្រមូលទិន្នន័យទាក់ទងនឹងចំនួន ឬលេខ ដោយសួរសំណួរបង្រួម និងប្រើប្រាស់កម្មវិធីស្ថិតិដើម្បីវិភាគ។ ពាក្យដែលត្រូវបានប្រើញឹកញាប់ក្នុងវិធីបែបបរិមាណវិស័យមាន "How many, test, verify, how often, or how satisfy...etc".

C). វិធីចម្រុះ (Mix Research): វិធីនេះអាចត្រូវបានគេប្រើប្រាស់វិធីគុណវិស័យ និងបរិមាណវិស័យជាមួយគ្នា។

# IV. ការជ្រើសរើសវិធីសាស្ត្រស្រាវជ្រាវ

១. ការគណនាសំណាក (Sample Size calculation for Quantitative)៖ សម្រាប់ការគណនាសំណាកនៃការស្រាវជ្រាវបែបបរិមាណវិស័យគេត្រូវគណនាចំនួនត្រឹមត្រូវដើម្បីបានភាពជាតំណាង (To be representative)។ មានរូបមន្តច្រើនក្នុងការគណនាសំណាក។ រូបមន្តរបស់លោក Slovin ក៏ត្រូវបានគេពេញនិយមក្នុងការប្រើប្រាស់ផងដែរ។

| | |
|---|---|
| | **n= N/1+N(e)2** |
| Where | **N** is total population |
| | **n** is sample we want to select |
| | **e** is margin error |

# IV. ការជ្រើសរើសវិធីសាស្ត្រស្រាវជ្រាវ

២.ការជ្រើសរើសសំណាក (How to select sample size)៖ សំណាក គឺជាក្រុមមនុស្ស ឬវត្ថុដែលយើងត្រូវជ្រើសរើសមកសិក្សាឬសម្ភាសន៍ដែលតំណាងអោយចំនួនមនុស្សឬវត្ថុទាំងមូល។ ការជ្រើសរើសំណាកមាន២បច្ចេកទេសគឺ ការជ្រើសរើសដោយចៃដន្យ (Probability sampling) និង ការជ្រើសរើសដោយមិនចៃដន្យ (Non probability sampling)។

a). ការជ្រើសរើសដោយចៃដន្យ(Probability Sampling)៖ ការស្រាវជ្រាវបែបបរិមាណវិស័យ (Quantitative Research) ត្រូវការជ្រើសរើសភាពជាតំណាង។

# IV. ការជ្រើសរើសវិធីសាស្ត្រស្រាវជ្រាវ

១-ការជ្រើសរើសតាមការចៃដន្យធម្មតា (Simple random sampling)៖ សំណាកអាចមានឱកាសស្មើគ្នាក្នុងការជ្រើសរើសរួមមាន ការចាប់ឆ្នោត ប្រើលេខចៃដន្យ...



Simple Random Sampling

# IV. ការជ្រើសរើសវិធីសាស្ត្រស្រាវជ្រាវ

២- ការជ្រើសរើសដោយប្រព័ន្ធ (Systematic sampling)៖ វត្ថុ ឬមនុស្សទាំងអស់ត្រូវបានរៀបចំជាលំដាប់លំដោយ ដូចជា មានស្រាប់នៅក្នុងបញ្ជីការចែកផ្លូវ ឬអាគារ។ល។



# IV. ការជ្រើសរើសវិធីសាស្ត្រស្រាវជ្រាវ

៣- ការជ្រើសរើសតាមចំណាត់ថ្នាក់(Stratified sampling)៖ ចែកមនុស្សទាំងអស់ទៅជាក្រុមតូចៗ ដូចជា ភេទនៃអ្នកចូលរួម អាយុ ឬកម្រិតនៃការអប់រំ។




Stratified Random Sampling

# IV. ការជ្រើសរើសវិធីសាស្ត្រស្រាវជ្រាវ

៤- ការជ្រើសរើសជាក្រុម (Cluster Sampling)៖ មនុស្សទាំងអស់ត្រូវបែងចែកជាក្រុមតូចៗ។ ដំណាក់កាលទី១ សំណាកត្រូវបានជ្រើសចេញពីចេញពីក្រុមតូចៗ។ ដំណាក់កាលទី២ មានតែសំណាកមួយត្រូវបានគេជ្រើសរើសចេញពីក្រុមតូចៗទាំងនេះ។



# IV. ការជ្រើសរើសវិធីសាស្ត្រស្រាវជ្រាវ

b). ការជ្រើសរើសដោយមិនចៃដន្យ(Non-Probability Sampling)៖ ការស្រាវជ្រាវបែបគុណវិស័យ(Qualitative Research)៖

១– Quota Sampling:

សំណាកត្រូវបានជ្រើសចេញពីក្រុមពិសេសណាមួយមកសិក្សា។ Ex. អ្នកស្រាវជ្រាវអាចសម្ភាសន៍ស្រីចំនួន១០០នាក់នៅក្នុងភូមិ ឬអ្នកមានអាយុពី១៥ទៅ១៨ឆ្នាំ។



# IV. ការជ្រើសរើសវិធីសាស្ត្រស្រាវជ្រាវ

២–Purposive Sampling: សំណាកត្រូវបានជ្រើសត្រូវនឹងលក្ខខណ្ឌស្រាវជ្រាវ និងយើងចង់បាន។



# IV. ការជ្រើសរើសវិធីសាស្ត្រស្រាវជ្រាវ

៣- Convenience Sampling: សំណាកត្រូវបានជ្រើសផ្អែកតាមការងាយស្រួលរបស់អ្នកស្រាវជ្រាវ។



# IV. ការជ្រើសរើសវិធីសាស្ត្រស្រាវជ្រាវ

៤- Snowball Sampling: សំណាកត្រូវបានជ្រើសរើសបន្តគ្នាពីអ្នកចូលរួមមួយអោយព័ត៌មានទៅសួរម្នាក់ទៀត។



# IV. ការជ្រើសរើសវិធីសាស្ត្រស្រាវជ្រាវ

២.របៀបសម្ភាសន៍ (Interview)៖ សម្ភាសន៍មានគោលបំណងប្រមូលរាល់ព័ត៌មានដែលទាក់ទងនឹងបញ្ហានៃការស្រាវជ្រាវដើម្បីយកមកវិភាគ។ ការសម្ភាសន៍មានបីយ៉ាង៖

a). ការសម្ភាសន៍ដែលគ្មានរចនាសម្ព័ន្ធ (Unstructured interviewing): ជាធម្មតាគេប្រើប្រាស់សម្រាប់ស្រាវជ្រាវជីវប្រវត្តិ។ (សម្រាប់តែវិធីសាស្ត្រស្រាវជ្រាវបែបគុណវិស័យ)។ សំណួរមិនត្រូវបានរៀបចំជាមុនផ្ទុយពីស្តង់ដារ Interview ដែលអ្វីត្រូវបានរៀបចំជាស្រេច។ការសម្ភាសន៍ប្រៀបដូចជាការនិយាយលេងក្នុងលក្ខណៈជីវិតប្រចាំថ្ងៃ។ ជាទូទៅគេប្រើសំណួរបើក។

# IV. ការជ្រើសរើសវិធីសាស្ត្រស្រាវជ្រាវ

ចំនុចសំខាន់នៃUnstructured Interview

១. លក្ខណៈវិនិច្ឆ័យ

- ពង្រាងសំណួរ (Light Structured and preparation)៖ អ្នកសម្ភាសន៍គ្រាន់តែដាក់សំណួរគោលទៅអោយគាត់ឆ្លើយ ប៉ុន្តែត្រូវស្ទង់ឬរាវសំណួរក្បែរៗនោះ។
- សំណួរបើក (Open ended question)៖ តម្រូវឲ្យអ្នកសួរអត្ថាធិប្បាយច្រើនអំពីអំណះអំណាង។ អាចទទួលបានចម្លើយប្លែក និងស៊ីជ្រៅ។ វាផ្ទុយពីសំណួរបិទ។
- សំណួរស្ទង់បែបកណ្តាល ឬ មិនជំរុញអោយឆ្លើយ (Neutral probes/non-biased encouragement)៖ អ្នកសម្ភាសន៍ត្រូវតែចៀសវាងការសួរលម្អៀងសម្រាប់ការសន្ទនាដើម្បីឲ្យអ្នកឆ្លើយមានសេរីភាពក្នុងការឆ្លើយ។

# IV. ការជ្រើសរើសវិធីសាស្ត្រស្រាវជ្រាវ

– ស្ងាត់ស្ងៀម (Silence)៖ វាស្រដៀងគ្នានឹងនឹងវិធីសម្ភាសន៍ដែលគ្មានគម្រោងអំពីជីវភាពប្រចាំថ្ងៃ។ ពេលខ្លះការមិនមាត់ ឬរង់ចាំស្តាប់អាចទទួលបានចម្លើយដែលយើងស្មានមិនដល់។ សម្រាប់ (Qualitative)។

២. គុណសម្បត្តិ

– បញ្ហាស្មុគ្រស្មាញអាចស្រាយបាន

– តែងតែងាយស្រួលសម្រាប់ការការសម្ភាសន៍គ្មានគ្រោង

– រក្សាគុណភាពទំនាក់ទំនងបានល្អ

៣. គុណវិបត្តិ

– ប្រើពេលច្រើន

– អាចមានឪកាសលម្អៀងច្រើន

– មានអារម្មណ៍ថាពិបាកប្រៀបធៀបគំនិត

# IV. ការជ្រើសរើសវិធីសាស្ត្រស្រាវជ្រាវ

ឧទាហរណ៍ (Unstructured Interview )៖ នៅទីតាំងដែលយើងចុះទៅសួរលើកដំបូង អ្នកគួរតែមានការសន្ទនាខ្លះៗអំពីភាពផ្សេងគ្នានៃជំងឺរបស់ក្មេងនៅក្នុងសហគមន៍។ ការសន្ទនាដូចខាងក្រោម៖

Researcher: តើក្មេងៗក្នុងភូមិនេះកើតមានជំងឺអ្វីខ្លះ?

Caregiver: “ បាទ ជាធម្មតាមានរាគរូស ក្តៅក្អក ផ្តាសសាយ និងគ្រុនពោះវៀន

Researcher: “ តើមានអ្វីផ្សេងទៀតទេ? តើមានអ្វីទៀតដែលកើតឡើងជាទូទៅនៅពេលអាកាសធាតុក្តៅ ឬត្រជាក់ខ្លាំង?

Researcher: “ តើលោកអាចប្រាប់យើងបានទេអំពីរោគកញ្ជ្រិល? ”

Caregiver: “ នៅពេលឈឺកញ្ជ្រិលត្រូវមុជទឹកត្រជាក់អោយក្មេង ពីព្រោះកញ្ជ្រិលក្តៅណាស់ ហើយក្មេងគួរដាក់ឲ្យនៅឆ្ងាយពីក្មេងដទៃ។

Researcher: “ ហេតុអ្វីត្រូវដាក់គេឲ្យនៅឆ្ងាយពីក្មេងដទៃ? ”

Caregiver: “ ពីព្រោះកញ្ជ្រិលអាចឆ្លងយ៉ាងងាយ“

……………………………………………………………………………………

# IV. ការជ្រើសរើសវិធីសាស្ត្រស្រាវជ្រាវ

b) សំណួរពាក់កណ្ដាលគ្រោង (Semi-structured Interview)៖

-សំណួរត្រូវបានគ្រោងខ្លះជាមាតិកាឬខ្លឹមសារសំខាន់ៗក្នុងគោលបំណងរុករកចម្លើយទូលាយពីអ្នកឆ្លើយ ប៉ុន្តែមិនអោយចាកប្រធានបទ។

- អ្នកសម្ភាសន៍ និងអ្នកដែលត្រូវគេសម្ភាសន៍ស្ថិតក្នុងការសម្ភាសន៍ជាផ្លូវការ

- អ្នកសម្ភាសន៍ពង្រាងសំណួរ/ការណែនាំការសម្ភាសន៍។

- អ្នកសម្ភាសន៍ដើរតាមសេចក្ដីពង្រាង (Questionnaire guide) ប៉ុន្តែអាចខុសពីសំណួរខ្លះនៅពេលអ្នកឆ្លើយមិនចង់ឆ្លើយ។

- Semi-Structured interview អនុញ្ញាតឲ្យអ្នកឆ្លើយមានសេរីភាពក្នុងការឆ្លើយ។ វាល្អសម្រាប់ទិន្នន័យគុណវិស័យ។

# IV. ការជ្រើសរើសវិធីសាស្ត្រស្រាវជ្រាវ

ឧទាហរណ៍ Semi-structured

Interview (សំណួរ)៖

Researcher:

- តើអ្នកមានគំនិតដូចម្តេចចំពោះការចូលរួមរបស់ស្ត្រីក្នុងកិច្ចការនយោបាយ?

–តើអ្នកឃើញមានអ្វីប្រែប្រួលធំនៅពេលនេះ?

–តើអ្នកមានអារម្មណ៍ដូចម្តេចចំពោះការងាររបស់អ្នក?

ឧទាហរណ៍ Semi-structured

Interview (វាវាក probe)៖

Researcher:

- តើវាកើតឡើងនៅពេលណា? អ្នកណាទៀតដែលពាក់ព័ន្ធ? នៅពេលនោះអ្នកនៅឯណា?

–តើអ្នកអាចប្រាប់បន្ថែមទៀតទេអំពីអ្វីដែលបានកើតឡើង?

–គ្រាន់តែងក់ក្បាលរង់ចាំគាត់ឆ្លើយមិនចាំបាច់កាត់គាត់

# IV. ការជ្រើសរើសវិធីសាស្ត្រស្រាវជ្រាវ

c) ការសម្ភាសន៍ដែលបានគ្រោងទុក (Structured Interview)៖

ត្រូវបានគេទទួលស្គាល់ថា ជាសំណួរ/សម្ភាសន៍មានស្តង់ដារ។ ជាទូទៅត្រូវបានប្រើប្រាស់ក្នុងការស្រាវជ្រាវបែបបរិមាណវិស័យ។

-សំណួរត្រូវបានរៀបចំ ធ្វើតេស្ត សាកល្បងក្នុងតារាងទិន្នន័យយ៉ាងត្រឹមត្រូវមុនពេលយកទៅសម្ភាសន៍។

-សំណួរដាក់ចំគោលដៅដែលយើងចង់បាន

-វាមានលក្ខណៈជាលេខ numeric number

-គ្រប់អ្នកត្រូវសម្ភាសន៍ត្រូវបានប្រើប្រាស់កម្រងសំណួរតែ១

# IV. ការជ្រើសរើសវិធីសាស្ត្រស្រាវជ្រាវ

ឧទាហរណ៍ (structured Interview )៖

១. តើអ្នកជ្រើសរើសមុខវិជ្ជាអ្វី? 1 □ វិទ្យាសាស្ត្រពិត 2 □វិទ្យាសាស្ត្រសង្គម 99 □ផ្សេងៗ (បញ្ជាក់...........)

២. ហេតុអ្វីបានជាអ្នកជ្រើសរើសមុខវិជ្ជានេះ?

1 □ ចំណង់ចំណូលចិត្ត 2 □ គ្មានជ្រើស

3 □ ឪពុកម្តាយបង្ខំ 99 □ផ្សេងៗ (បញ្ជាក់.........)

៣. តើអ្នកមករៀនដោយមធ្យោបាយអ្វី?

1□ ដើរ 2 □ កង់ 3 □ ម៉ូតូ

4 □ ផ្សេងៗ (បញ្ជាក់.........................................................)

# IV. ការជ្រើសរើសវិធីសាស្ត្រស្រាវជ្រាវ

២. ពិភាក្សាក្រុម (FGD)៖ ការពិភាក្សាក្រុមជាឧបករណ៍ស្រាវជ្រាវមួយដ៏ល្អក្នុងការប្រមូលព័ត៌មាន។

-ក្រុមអាចដំណើរការទៅបានល្អអាស្រ័យលើអ្នកសម្របសម្រួលក្រុមដែលណែនាំប្រធានបទច្បាស់លាស់សម្រាប់ការពិភាក្សា ដែលអ្នកចូលរួមអាចពិភាក្សាដោយសេរី និងរស់រវើក។



-ចំណុចសំខាន់តើក្រុមយល់ព្រមឬមិនយល់ព្រមលើជាមួយគ្នាទៅលើការគិតលើបញ្ហារបស់ក្រុម។

# IV. ការជ្រើសរើសវិធីសាស្ត្រស្រាវជ្រាវ

| គុណសម្បត្តិនៃ FGD | គុណវិបត្តិនៃ DGD |
| --- | --- |
| - ចម្លើយតបរបស់ក្រុម<br>- អ្នកចូលរួមមានឱកាសសួរគ្នាទៅវិញទៅមក<br>- អាចជួយនរណាម្នាក់ដែលផ្សេងបញ្ហា<br>- មានទម្លាប់ជួយគ្នាក្នុងក្រុម<br>- ឥទ្ធិពលរបស់ក្រុមមានប្រយោជន៍សម្រាប់ការវិភាគ<br>- អន្តរកម្មរបស់អ្នកចូលរួមមានប្រយោជន៍សម្រាប់វិភាគ | - សមាជិកក្រុមខ្លះមានអារម្មណ៍មិនសូវស្រួល<br>- អ្នកខ្លះអសកម្ម<br>- អ្នកខ្លះអាចឆ្លើយតាមគេ<br>- អ្នកស្រាវជ្រាវពិបាកក្នុងការសម្របសម្រួលក្រុម<br>- សម្ភារៈមួយចំនួនអាចថ្លៃ<br>- ពិបាកទាញចេញនូវការវិភាគលក្ខណៈបុគ្គល |

# IV. ការជ្រើសរើសវិធីសាស្ត្រស្រាវជ្រាវ

២. ការកសាងសំណួរ (Questionnaires Design)៖ សំណួរជាឧបករណ៍ចាំបាច់មួយសម្រាប់ប្រមូលទិន្នន័យនៃការស្រាវជ្រាវ។ វាត្រូវបានរៀបចំឡើងដោយផ្អែកលើគោលបំណង និងសំណួរស្រាវជ្រាវជ្រាវ។ ប្រភេទសំណួរមានបីប្រភេទ៖

a). សំណួរបើក (Open Ended Question)៖ បើកទូលាយឲ្យអ្នកឆ្លើយៗតាមការគិតរបស់គេ។ វាត្រូវបានរៀបចំឡើងដើម្បីបានចម្លើយពេញលេញ និងផ្តល់ជម្រើសឲ្យអ្នកឆ្លើយ។ Ex.

១. តើអ្នកបានចូលអានក្នុងបណ្ណាល័យញឹកញាប់ទេ?

១. ញឹកញាប់ណាស់ ២. ញឹកញាប់គ្រាន់បើដែរ

៣. មិនសូវញឹកញាប់ទេ ៤. កម្រណាស់

៥. មិនដែលទាល់តែសោះ

២. ប្រសិនបើមិនដែលទាល់តែសោះតើមូលហេតុអ្វី?

...........................................................................................

# IV. ការជ្រើសរើសវិធីសាស្រ្តស្រាវជ្រាវ

b). សំណួរបិទ (Close Ended Question)៖ ចម្លើយត្រូវបានដាក់អោយអ្នកឆ្លើយជ្រើសរើស ដើម្បីអោយត្រូវនូវអ្វីដែលយើងចង់បាន។ វាងាយស្រួលវិភាគតាមកម្មវិធីស្ថិតិ ពីព្រោះវាជាចំនួន។ Ex.

១. តើអ្នកចូលចិត្តអានទេសព្វថ្ងៃនេះ?

១. បាទចូលចិត្ត ២. ទេ មិនចូលចិត្តទេ

២. តើចង់ប្រឡងជាប់ដែរឬទេ?

១. បាទ ២. ទេ

# IV. ការជ្រើសរើសវិធីសាស្ត្រស្រាវជ្រាវ

c). សំណួរចម្រុះ (Combination of Both Questions)៖ ជាប្រភេទសំណួរដែលមានចម្លើយបិទផង និងចម្លើយទូលាយផង។ Ex.

១. តើអ្នកចូលចិត្តអានទេសព្វថ្ងៃនេះ?

១. បាទចូលចិត្ត ២. ទេ មិនចូលចិត្តទេ

១.១ បើបាទ/ចាស តើហេតុអ្វី? ................................

១. ២ បើទេ តើហេតុអ្វី? ..........................................

# IV. ការជ្រើសរើសវិធីសាស្ត្រស្រាវជ្រាវ

៣. ការប្រមូលទិន្នន័យ (Data Collection)៖

A) ទិន្នន័យបឋម (Primary Data)៖ ជាទិន្នន័យដំបូងដែលមិនទាន់ត្រូវបានគេយកទៅប្រើប្រាស់។

- ទិន្នន័យទាក់ទងនឹងមនុស្ស
- ជាការអង្កេតរបស់អ្នកស្រាវជ្រាវ
- ជាបទពិសោធន៍របស់អ្នកស្រាវជ្រាវ
- ជាអត្ថបទ ឬកំណាត់ហេតុប្រវត្តិសាស្ត្រ
- របាយការអង្គភាព
- ឯកសារផ្ទាល់ខ្លួន
- ទិន្នន័យស្ថិតិ
- វីដេអូ

# IV. ការជ្រើសរើសវិធីសាស្ត្រស្រាវជ្រាវ

៣. ការប្រមូលទិន្នន័យ (Data Collection)៖

B) ទិន្នន័យបន្ទាប់បន្សំ (Secondary Data)៖ ជាទិន្នន័យដែលត្រូវបានគេយកស្រាយរួចហើយ ឬជាព័ត៌មានដែលគេបានបោះពុម្ព ឬសិក្សាស្រាវជ្រាវមុនៗ ដូចជា៖

- សៀវភៅស្រាវជ្រាវ
- របាយការណ៍របស់អ្នកស្រាវជ្រាវ
- អត្ថបទការសែត ទស្សនាវដ្ដី
- អត្ថបទដែលគេផលិតឡើងវិញតាមប្រព័ន្ធអ៊ីនធ័រណិត
- ការពិភាក្សាវិទ្យាសាស្ត្រ
- ការរិះគន់លើសិល្បៈឬអក្សរសិល្ប៍
- ការវិភាគលើព្រឹត្តការណ៍ប្រវត្តិសាស្ត្រ

# IV. ការជ្រើសរើសវិធីសាស្រ្តស្រាវជ្រាវ

៣. ការប្រមូលទិន្នន័យ (Data Collection)៖

+ វិធីប្រមូលទិន្នន័យបែបបរិមាណវិស័យ (Survey)
   - ជាលេខ ឬចំនួន
   - ជាទំនាក់ទំនងហេតុផល
   - ជាការពិសោធន៍
   - មានលក្ខណៈវត្ថុវិស័យភាព
+ វិធីប្រមូលទិន្នន័យបែបបគុណវិស័យ
   - ជាអត្ថបទ
   - ជាការយល់ដឹងរបស់មនុស្ស
   - ជាការបកស្រាយ
   - មានលក្ខណៈប្រធានវិស័យភាព

# IV. ការជ្រើសរើសវិធីសាស្ត្រស្រាវជ្រាវ

៤. ការវិភាគទិន្នន័យ (Data Analysis)៖

\+ សម្រាប់ទិន្នន័យបែបបរិមាណវិស័យ (Quantitative Data)៖

- ប្រើប្រាស់កម្មវិធីកុំព្យូទ័រដើម្បីវិភាគ ដូចជា Excel, SPSS ជាដើម។

\+ សម្រាប់ទិន្នន័យបែបគុណវិស័យ (Qualitative Data)៖

– ប្រើប្រាស់ទម្រង់សង្ខេប និងធ្វើការបកស្រាយ

# V. ទម្រង់សំណើស្រាវជ្រាវ

សំណើស្រាវជ្រាវល្អមួយត្រូវមាន៖

1) ចំណងជើង (ប្រធានបទ) : ជាពាក្យឬឃ្លាដែលអាចពន្យល់បាន

2) សេចក្តីផ្តើមឬលំនាំបញ្ហា៖ ជាកថាខណ្ឌបើកទូលាយបង្ហាញអំពីទស្សនៈទូទៅអំពីអ្វីដែលកើតមានឡើងជុំវិញប្រធានបទ ដើម្បីនាំអ្នកអានរបស់អ្នកយល់ដឹងអំពីបញ្ហា ដែលអ្នកនឹងត្រូវរុករក។

# V. ទម្រង់សំណើស្រាវជ្រាវ

៣. គោលបំណង៖ លើកឡើងបង្ហាញអ្វីដែលជាគោលបំណងធំ ឬគោលដៅ ដែលអ្នកនឹងត្រូវសរសេរក្នុងការស្រាវជ្រាវ។

៤. សំណួរស្រាវជ្រាវ៖ ដាក់ចេញសំណួរដែលសំខាន់ៗដែលអ្នកនឹងត្រូវឆ្លើយក្នុងការស្រាវជ្រាវ។ ពីចំណុចទី១រហូតចំណុចចុងក្រោយ។

៥. សម្មតិកម្ម៖ ជាការសន្និដ្ឋានចម្លើយទុកមុនសម្រាប់ធ្វើការសិក្សាស្រាវជ្រាវ។ សម្មតិកម្មគួរមានលើសពីមួយ។

# V. ទម្រង់សំណើស្រាវជ្រាវ

៦. វិធីសាស្ត្រស្រាវជ្រាវ៖ តើអ្នកនឹងធ្វើការសិក្សាដោយរបៀបណា? ដូចជាការប្រមូលព័ត៌មាន ការវិភាគព័ត៌មាន។ រួមមាន៖

- ការប្រមូលទិន្នន័យ៖ របៀបប្រមូលព័ត៌មាន។ ទិន្នន័យបឋម និង ទិន្នន័យបន្ទាប់បន្សំ ។ ទិន្នន័យបែបគុណវិស័យ ឬបរិមាណវិស័យ។
- ការជ្រើសរើសសំណាក៖ តើអ្នកនឹងសម្ភាសន៍អ្នកណាខ្លះ? ប៉ុន្មាននាក់?
- ទីកន្លែងស្រាវជ្រាវ៖ តើការស្រាវជ្រាវរបស់អ្នកធ្វើឡើងនៅកន្លែងណា? ស្រុកណា? ភូមិណា? តំបន់ណា?

# V. ទម្រង់សំណើស្រាវជ្រាវ

៧. សារៈសំខាន់នៃការស្រាវជ្រាវ៖ បង្ហាញថា ហេតុអ្វីបានជាអ្នកគិតថា ការស្រាវនេះសំខាន់សម្រាប់អ្នកក្នុងការធ្វើការសិក្សាស្រាវជ្រាវ?

៨. រំលឹកទ្រឹស្តី៖ តើមានឯកសារអ្វី ? ការសែត អត្ថបទ អ្វីដែលអ្នកធ្វើជាបង្អែកក្នុងការសិក្សាស្រាវជ្រាវនេះ?

៩. តារាងពេលវេលា៖ តើអ្នកចាប់ផ្តើមនៅពេលណា? បញ្ចប់នៅពេលណា?

# V. ទម្រង់សំណើស្រាវជ្រាវ

| ***សកម្មភាព*** | ***ពេលវេលា*** | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | Apr | May | Jun | Jul | Aug | Sep | Oct | Nov | Dec |
| រៀបចំសំណើស្រាវជ្រាវ និងវិធីសាស្ត្រស្រាវជ្រាវ | | | | | | | | | |
| ប្រមូលទិន្នន័យ | | | | | | | | | |
| បញ្ចូល និងវិភាគទិន្នន័យ | | | | | | | | | |
| សរសេររបាការណ៍ស្រាវជ្រាវ | | | | | | | | | |

# VI. ទម្រង់សំណើស្រាវជ្រាវ

១០. ថវិការ៖ តើអ្នកប្រើប្រាស់ថវិកា និងសម្ភារៈប៉ុន្មានសម្រាប់ការសិក្សាស្រាវជ្រាវនេះ?

១១. ឯកសារយោង៖ ព័ត៌មានដែលអ្នកអានទាក់ទងនឹងប្រធានបទ។

# VI. ឯកសារពិគ្រោះ

1. Chava Frankfort-Nachmias and Devid Nachmias: **RESEARCH MEHTOD IN THE SOCIAL SCIENCES**,St.Martin Press, New York. Fifth Edition,1996.

2. Dr Catherine Dawson: **PRACTICAL RESEARCH METHODS**, Oxford, United Kingdom,2002.